00244221

D97/6

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 03 / DEC / 2008
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fay

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

សំណុំរឿងព្រហ្មទណ្ឌ
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**

**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 002/19-09-2007-ECCC-OCIJ**

# ដីកាសម្រេចអំពីការស្នើសុំបន្ថែមចំនួនទំព័រកំណត់
# Ordonnance sur demande d'extention de nombre de pages
# Order on Request for Extension of Page Limit

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 04 / DEC / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fay

យើង **យូ ប៊ុនឡេង** និង Marcel LEMONDE (ម៉ាសែល ឡឺម៉ុង) ចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក.")

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **អៀង សារី** ហៅវ៉ាន់ កើតថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩២៥ ដែលត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យចំពោះ **ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** និង **ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩** បទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និងច្បាប់ផ្សេងៗទៀត

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

បានឃើញវិធាន៣៩ នៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក "វិធានផ្ទៃក្នុង"

បានឃើញមាត្រា៥ នៃសេចក្តីណែនាំអនុវត្ត ស្តីពីការដាក់ឯកសារនៅចំពោះមុខអ.វ.ត.ក (សេចក្តីណែ នាំអនុវត្ត)

បានឃើញដីកាសម្រេចលើពាក្យស្នើសុំអនុវត្ត នៅចំពោះមុខ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានគេស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០០៨ (D97/III)។

បានឃើញសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំបន្ថែមនូវចំនួនទំព័រលើចំនួន ដែលមាននៅក្នុងកំណត់សម្គាល់របស់ខ្លួន ទាក់ទិននឹងសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៨ (D97/4)

បានឃើញសំណើរបស់ **អៀង សារី** ស្នើសុំឱ្យមានការបន្ថែមនូវចំនួនទំព័រ ដើម្បីធ្វើកំណត់សម្គាល់បន្ថែម ទាក់ទិននឹងការស្នើសុំអនុវត្តទំរង់នៃសហឧក្រិដ្ឋកម្មរួម នៅចំពោះមុខ អ.វ.ត.ក. ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ (D97/5)

## ការរំលឹកឡើងវិញអំពីនីតិវិធី

១. នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨ **អៀង សារី** បានធ្វើការតវ៉ាចំពោះភាពដែលអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម (JCE) នៅចំពោះមុខតុលាការនេះ (D97)។

២. អនុលោមតាមដីកាចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ យើងបានអញ្ជើញគ្រប់ភាគីទាំងអស់ឱ្យចូលរួមធ្វើការដាក់ជូននូវកំណត់សម្គាល់របស់ខ្លួនទាក់ទិននឹងបញ្ហានេះ ឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

00244223



៣. នៅក្នុងការដាក់ឯកសារដោយឡែកផ្សេងគ្នាកាលពីថ្ងៃទី ២១ និង ២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ **អៀង សារី** និងសហព្រះរាជអាជ្ញាបានដាក់នូវសំណើសុំបន្ថែមចំនួនទំព័រទៅលើចំនួនដែលបានកំណត់ពី ១៥ទំព័រ ទៅ ៣០ទំព័រ។

## ការរំលឹកឡើងវិញអំពីច្បាប់ដែលត្រូវអនុវត្ត

៤. យោងតាមវិធានផ្ទៃក្នុងមាត្រា៣៩(៦) មាត្រា៥.១ និង៥.៤ នៃសេចក្តីណែនាំអនុវត្តបានចែងថា ឯកសារទាំងអស់ដែលដាក់ជូនទៅសហចៅក្រមស៊ើបអង្កេត មិនត្រូវឱ្យលើសពី ១៥ទំព័រឡើយជាភាសាអង់គ្លេស។ វាលែងតែមានសំណើពីភាគីណាមួយ ចៅក្រមអាចធ្វើការពិចារណានូវកាលទេសៈពិសេស និងអនុញ្ញាតឱ្យមានការបន្ថែមនូវចំនួនទំព័រដែលត្រូវបានកំណត់។

## ការកត់សម្គាល់របស់ភាគី

៥. នៅក្នុងសំណើរបស់ខ្លួន សហព្រះរាជអាជ្ញាបានស្នើឱ្យមាននូវករណីពិសេសនានា ដោយសំអាងថា ចំនួនទំព័រដែលអនុញ្ញាតិគឺមានលក្ខណៈមិនគ្រប់គ្រាន់ដើម្បី "អាចបញ្ជាក់ឆ្លើយតបបានចំពោះគ្រប់ទិដ្ឋភាពសំខាន់ៗទាំងអស់នៃបញ្ហា" ដែល"សារៈសំខាន់ជាក់ស្តែង" ហើយនិងភាពស្មុំញ៉ាំដែលនៅក្នុងនោះ "សហចៅក្រមស៊ើបអង្កេតបានទទួលស្គាល់ (តាមរយៈការផ្តល់ឱ្យ) នូវពេលវេលាដ៏សមរម្យមួយសម្រាប់ភាគីដើម្បីធ្វើការដាក់ជូននូវការកំណត់សម្គាល់នានា។ សហព្រះរាជអាជ្ញា ក៏បានធ្វើការកត់សម្គាល់នូវតំរូវការក្នុងការឆ្លើយតបទៅនឹងការទទ្បីករណ៍នានា ដែលមាននៅក្នុងសារណាអ្នកដែលមិនមែនជាភាគី (Amicus Curiae) ដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ ហើយបានលើកឡើងនូវតម្រូវការក្នុងការឆ្លើយតបជាលក្ខណៈបុគ្គលចំពោះជនជាប់ចោទនីមួយៗ។ ជាចុងក្រោយ ពួកគេបានធ្វើការកត់សម្គាល់អំពីតម្រូវការក្នុងការលើកឡើងនូវឯកសារស្រាវជ្រាវមួយចំនួនធំ ហើយនិងយុត្តិសាស្ត្រ ដែលទាក់ទិននឹងបញ្ហានេះ (កថាខ័ណ្ឌ ២-៣)។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES * BUREAU DES CO-JUGES D'INSTRUCTION

៦. សំណើររបស់ **អៀង សារី** ក៏បានលើកឡើងផងដែរអំពីកាលទេសៈពិសេស ដោយសំអាងលើការផ្តល់ឱ្យដោយសហចៅក្រមស៊ើបអង្កេត ហើយនឹងតម្រូវការក្នុងការឆ្លើយតបទៅនឹងបញ្ហាថ្មីៗដែលបានលើកឡើងដោយអង្គបុរេជំនុំជម្រះ amici (កថាខ័ណ្ឌ ១-៣)។

## ហេតុផលនៃសេចក្តីសម្រេច

៧. យល់ឃើញថា ហេតុផលដែលថារយៈពេលដ៏វែងមួយត្រូវបានផ្តល់ឱ្យភាគីទាំងឡាយដើម្បីដាក់ជូននូវការកត់សម្គាល់របស់ខ្លួនទាក់ទងនឹង JCE មិនត្រូវបានហៅថាជាករណីពិសេស ដែលអាចទទួលបាននូវការបន្ថែមនូវចំនួនទំព័រកំណត់ទេ ផ្ទុយទៅវិញ ពេលវេលានេះគឺគ្រប់គ្រាន់ក្នុងការរៀបចំនូវចម្លើយ ដែលមានលក្ខណៈសង្ខេប ហើយច្បាស់លាស់ ហើយក៏មិនមែនមានន័យថា វត្តមានរបស់ជនជាប់ចោទជាច្រើនទាមទារនូវការពិចារណាដាច់ៗពីគ្នាលើបញ្ហា ដែលមានលក្ខណៈរួមគ្នាសម្រាប់ពួកគេទាំងអស់នោះដែរ។

៨. ប៉ុន្តែ យល់ឃើញពីសារៈសំខាន់ និងភាពស្មុគស្មាញដ៏ធំធេងនៃអង្គច្បាប់ និងយុត្តិសាស្ត្រមួយចំនួនដែលពាក់ព័ន្ធ រួមទាំងបញ្ហាទាំងឡាយដែលត្រូវបានលើកឡើងនៅក្នុងសារណារបស់អ្នកមិនមែនភាគីដែលបានដាក់ជូនចំពោះអង្គបុរេជំនុំជម្រះ។

៩. លើសពីនេះ យល់ឃើញថា ការបន្ថែមនូវចំនួនទំព័រដែលត្រូវបានកំណត់សម្រាប់គ្រប់ភាគី នឹងបង្ការដល់ការប៉ះពាល់នានាដល់សិទ្ធិរបស់ពួកគេ។

00244225

ការ/ន:(៦) ១១/៦

**ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតសម្រេច÷**

- យល់ស្របតាមសំណើរបស់សហព្រះរាជអាជ្ញា និងរបស់ អៀង សារី ។

- ទទួលយកសារណា ដែលមានភ្ជាប់ជាមួយនឹងសំណើរបស់ **អៀង សារី** ។

- អនុញ្ញាតឲ្យភាគីដទៃផ្សេងទៀតដែលទាក់ទិននឹងករណីនេះ អាចធ្វើការដាក់ជូនកំណត់សម្គាល់របស់ខ្លួន មិនឲ្យលើសពី៣០ទំព័រ ស្តីពីការអនុវត្តន៍ទម្រង់នៃសហឧក្រិដ្ឋកម្មរួម (JCE) នៅចំពោះមុខ អ.វ.ត.ក។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៨

**សហចៅក្រមស៊ើបអង្កេត**

**Co-Investigating Judges**

**Co-juges d'instruction**

MARCEL Lemonde

យូ ប៊ុនឡេង



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.